# វិធីដាំខ្នុរ

## ១.ការជ្រើសរើសពូជ:

- គួរជ្រើសរើសពូជខ្នុរបំបៅពីព្រោះវាមានផ្លែសុទ្ធល្អនិងឆាប់បានផ្លែ ។
- រើសយកពូជខ្នុរមានខ្លែបច្រើនសាច់ក្រាស់ ។

## ២.ការរៀបចំរណ្ដៅ:

- ត្រូវជីករណ្ដៅ៨តឹកបួនជ្រុង និង ជំរៅ៨តឹក




- រោយកំបោរសនិងថ្នាំកណ្ដៀរ (FURADAN) ប្រមាណ២ស្លាបព្រាបាយក្នុងរណ្ដៅ ។
- ត្រូវដាក់ផេះឬអង្កាម,កំប្លោក,ចំបើងពុក,អាចម៍គោមាន់-ជ្រូកមួយស្រទាប់




កំរាស់១តឹករួចដាក់ដីពីលើ១តឹកធ្វើយ៉ាងនេះរហូតទាល់តែពេញកំពុងរណ្ដៅ ។

- ត្រូវទុករណ្ដៅរៀបចំហើយក្នុងរយៈពេល២ ទៅ ៣ អាទិត្យ ។
- ចំងាយពីរណ្ដៅមួយទៅរណ្ដៅមួយទៀត មានប្រវែង៨ម៉ែត្រ ។

## ២.ការដាំ:

- កូនខ្នុរត្រូវរក្សាផ្សាំទុក១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹកកូនខ្នុរ២ថ្ងៃមុនដាំ ។
- មុនដាំត្រូវជញ្ជូនកូនដាក់ក្បែររណ្ដៅ ។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- ដាំកូនខ្នុរក្នុងរណ្ដៅ រួចកប់ក្នុងដីដោយរក្សាថង់រុំបំបៅនៅលើដីប្រហែល១ថ្នប់ដៃ ។
- លប់ដីដោយសង្កត់ថ្នមៗរួចយកមែកឈើដោតក្បែររណ្ដៅចងទប់ជាមួយកូនខ្នុរ ។




## ៣.ការថែទាំនិងដាក់ជី:

- កាត់ថង់រុំបំបៅចេញក្រោយដាំបាន១ខែ ។
- ខែវស្សារត្រូវពូនគល់ការពារទឹកលិច ។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉នដោយប្រើជី១៥-១៥-១៥ (៣ខាំ)លាយជាមួយជីអាចម៍គោ,មាន់,ជ្រូក,(៣បង្គី)អង្កាម,ចំបើងរួចកាយកប់ក្នុងដីធ្វើជាកំពែង ។
- ប្រសិនបើកូនខ្នុរមានសត្វល្អិតស៊ីត្រួយត្រូវ
- ប្រើថ្នាំសំលាប់សត្វល្អិតឬថ្នាំ S85 (កាបារីល)សំរាប់ជំនួយស្លឹកនិងដើមលូតលាស់ល្អ ។



## ៤.ការស្រោចទឹក:

- កូនខ្នុរអាយុតិចជាង១ឆ្នាំត្រូវស្រោចទឹក២ដងក្នុង១អាទិត្យនៅរដូវប្រាំង ។
- យើងត្រូវស្រោចទឹក១ដងក្នុង១អាទិត្យនៅពេលវាកំពុងផ្កាដើម្បីការពារជ្រុះក្តិប ។

## ៥.ការកាត់តែងមែក:

- ត្រូវកាត់ត្រួយចុងចេញនៅឆ្នាំទីមួយ
- ត្រូវកាត់មែកមិនសូវល្អចេញ រៀងរាល់ឆ្នាំដោយទុកតាមប្រព័ន្ធ១-៣-៦-១៨(ដើម១-មែកធំ៣-ខ្នែងធំ៦និងខ្នែងត្រួយ១៨)បើអាចធ្វើបានជាការល្អ។



កាត់តែងមែកតាមប្រព័ន្ធ១-៣-៦-១៨

## ៦.ការប្រមូលផល:

- មិនត្រូវបេះផ្លែខ្នុរទំលាក់លើដី ។គួរឡើងបេះនិងដាក់ក្នុងសម្រែកបង្ហូតចុះក្រោម ។
- បើអាចធ្វើបាន,គួរកាត់ផ្លែខ្នុរអោយមានជាប់ទងជាការប្រសើរ ។



**អាចរកទិញកូនឈើហូបផ្លែបានតាមរយ:**

១-អ្នកស្រីជា ធារិទ្ធ,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរស្ពានទឹកវិល,ខ័ណ្ឌ-ក្រុងសៀមរាប,
ទូរស័ព្ទលេខ: 012 35 10 30/017 68 84 49

២-លោកគីម សុធា, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនបុប្ផាអង្គរ,ក្រុងសៀមរាប,
ទូរស័ព្ទលេខ: 012 98 06 23

៣- លោកគីម ឈុំ,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនច្បារអេដែន,ក្រុងសៀមរាប,
ទូរស័ព្ទលេខ: 012 31 20 55

៤-លោកវ៉ាន់ ហឿន,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរផ្សារអង្គ្រង,ស្រុកប្រាសាទបាគងខេត្តសៀមរាប,
ទូរស័ព្ទលេខ: 012 70 80 43

៥-អ្នកស្រីគីម សាវេត,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ភូមិស្ពានជ្រាវ,ខ័ណ្ឌ-ក្រុងសៀមរាប,
ទូរស័ព្ទលេខ: 089 80 54 66

**សំរបសំរួលដោយ**

**កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ខេត្តសៀមរាប**

FacilitatedbyRED-GreenBeltSiemReap

# ភាពជោគជ័យក្នុងការដាំខ្នុរ



## ការណែនាំអនុវត្តន៍ជាក់ស្តែងដោយ:

អ្នកស្រី **ជាធារិទ្ធ**,លក់ពូជឈើហូបផ្លែគ្រប់មុខ
អាស័យដ្ឋាន:ក្បែរស្ពានទឹកវិល,ខ័ណ្ឌសៀមរាប,
ក្រុងសៀមរាប,ទូរស័ព្ទលេខ:០១២៣៥១០៣០